## មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយឈ្មោះ សេង វ៉ា ភេទប្រុស អាយុ៦០ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ“យោធា”**

**ស្រុកកំណើតនៅភូមិបាកន ឃុំដងកាំបិត ស្រុកសណ្តាន់ ខេត្តកំពង់ធំ**

**រស់នៅភូមិសែនសុខ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ សោម ប៊ុនថន**

**០១:០៥:១១**

**២៥ទំព័រ**

ប៊ុនថនៈ កុំឲ្យខាតពេលខ្ញុំសុំសម្ភាសលោកតា និងខ្ញុំសុំថតជាសម្លេង?

វ៉ាៈ បាទ ។

ប៊ុនថនៈ ដោយសារខ្ញុំកត់មិនទាន់លោកតា?

វ៉ាៈ បាទ ។

ប៊ុនថនៈ លោកតាអនុញ្ញាតឲ្យខ្ញុំថតទេ លោកតា?

វ៉ាៈ បាទ ។

ប៊ុនថនៈ ចឹងជាដំបូងខ្ញុំសុំសួរឈ្មោះ លោកតា លោកតាឈ្មោះ អីដែរ?

វ៉ាៈ ខ្ញុំឈ្មោះ សេង វ៉ា ។

ប៊ុនថនៈ តាអាយុប៉ុន្មាន?

វ៉ាៈ ខ្ញុំអាយុ៦០ហើយ ។

ប៊ុនថនៈ តាមានស្រុកកំណើតនៅភូមិឃុំអីដែរ?

វ៉ាៈ នៅភូមិបាកន ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។

ប៊ុនថនៈ ឃុំអីវិញ?

វ៉ាៈ ឃុំដងកាំបិត ។

ប៊ុនថនៈ តាមានបងប្អូនប៉ុន្មាននាក់?

វ៉ាៈ ខ្ញុំមានបងប្អូនពីរនាក់ ។

ប៊ុនថនៈ ចឹងមានបងប្អូនពីនាក់?

វ៉ាៈ ខ្ញុំនិងប្អូនស្រីខ្ញុំម្នាក់ ឪពុកម្តាយស្លាប់តាំងពីនៅតូចឆ្នាំ៥៣-៥៤ម្តាយឪពុកស្លាប់ ។

ប៊ុនថនៈ ប្អូនស្រីតានៅរស់ដែរ?

ភ៉ៈ	គាត់នៅរស់រាល់ថ្ងៃគាត់នៅខាងស្រុកសណ្តាន់ ។

ប៊ុនថុនៈ	គាត់ឈ្មោះអីដែរ?

ភ៉ៈ	ប្អូនខ្ញុំឈ្មោះ រឿង ។

ប៊ុនថុនៈ	សេង រឿង?

ភ៉ៈ	ឈ្មោះ មឿង រឿង?

ប៊ុនថុនៈ	ម៉េចបានត្រកូលខុសគ្នា?

ភ៉ៈ	ត្រកូលគាត់ដាក់ជីតាខ្ញុំ បើខ្ញុំដាក់ឪពុកបណ្តោយ បើតាតែមួយទេ ឪពុកជាមួយគ្នាដែរ ។

ប៊ុនថុនៈ	ឪពុកពូគាត់ឈ្មោះអីដែរ?

ភ៉ៈ	ឈ្មោះ សេង ។

ប៊ុនថុនៈ	ត្រកូលគាត់?

ភ៉ៈ	ត្រកូលគាត់មិនដឹងស្អីទេ កើតមិនទាន់ផងហ្នឹង ។

ប៊ុនថុនៈ	ម្តាយពូ?

ភ៉ៈ	ម្តាយឈ្មោះ ឡុង ។

ប៊ុនថុនៈ	គាត់ស្លាប់ជំនាន់ណាពូ?

ភ៉ៈ	មើលតាំងពីឆ្នាំ៦៥-៦៦នោះ ។

ប៊ុនថុនៈ	ឆ្នាំហ្នឹង កាលហ្នឹងពូនៅអាយុប៉ុន្មានពូ?

ភ៉ៈ	ខ្ញុំអាយុ១៧ មិនអាយុ១៧ទេ ប្រហែលជា១៤-១៥ទេ កាលហ្នឹង ។

ប៊ុនថុនៈ	គាត់ស្លាប់ដោយសារអីពូ?

ភ៉ៈ	ជំងឺគាត់ឈឺទាំងម្តាយទាំងឪពុកនោះមិនដឹងជាឈឺយ៉ាងទេ បានកូនតែពីរនាក់គាត់ស្លាប់ ។

ប៊ុនថុនៈ	ស្លាប់ឆ្នាំដំណាលគ្នាឆ្នាំ១៩៦៥ហ្នឹង?

ភ៉ៈ	ឪពុកស្លាប់មុនប្រហែលជាបីឆ្នាំ បានម្តាយស្លាប់ក្រោយ ។

ប៊ុនថុនៈ	ចឹងឪពុកពូស្លាប់ឆ្នាំ៦៥ម្តាយពូស្លាប់ក្រោយប្រហែលជាឆ្នាំ៦៨អី?

ភ៉ៈ	បាទ!៦៨ ។

ប៊ុនថុនៈ	ចឹងពេលឪពុកម្តាយស្លាប់នៅជាមួយប្អូន?

ភ៉ៈ	នៅជាមួយអ៊ំ បងម្តាយបង្កើត ក្រោយមកនៅបានមួយឆ្នាំពីរឆ្នាំទទួល គេហៅកើតទាហានខ្មែរក្រហមនោះ ។

ប៊ុនថុនៈ	ពូមានបានចូលរៀនទេ?

ភ៉ៈ ខ្ញុំចូលរៀនបានត្រឹមថ្នាក់ទី១០ ពីសង្គម ឆ្នាំ៧០ទៅកើតមានរដ្ឋប្រហារទៅចប់ គ្រូរត់ឈប់អស់ទៅ ។

ប៊ុនថន: ពូរៀននៅសាលាណា?

ភ៉ៈ សាលាចុងកាត់មាត់ញុកគេហៅភូមិស្រែ នៅឃុំដងកាំបិតនោះ ភូមិស្រែ ។

ប៊ុនថន: ពូឈប់រៀនហ្នឹងពេលរដ្ឋប្រហារ?

ភ៉ៈ បាទ! ពេលឆ្នាំ៧០ពេលមានរដ្ឋប្រហារទៅគ្រូរត់ចេញអស់ទៅខ្ញុំក៏ឈប់ទៅ ចេញពីនោះមកមានអង្គការខ្មែរក្រហមគេទៅចលនា ។

ប៊ុនថន: ចលនាយ៉ាងម៉េចខ្លះពូ?

ភ៉ៈ ចលនាឲ្យធ្វើការតស៊ូប្រឆាំងជាមួយលន់ នល់ ចឹងខ្ញុំក៏នាំប្អូនចូលធ្វើបម្រើចលនាខ្មែរក្រហមហ្នឹងទៅតាំងពីឆ្នាំ៧០ហ្នឹង ។

ប៊ុនថន: មានចាំថ្ងៃខែដែលពូ?

ភ៉ៈ ថ្ងៃខ្ញុំមិនចាំទេ មើលឆ្នាំ៧០ខ្ញុំធ្វើនៅក្នុងភូមិដល់ឆ្នាំ១៩៧២ ខ្ញុំចូលបម្រើការងារនៅក្នុងស្រុកសណ្ដាន់ ។

ប៊ុនថន: ចឹងចូលដំបូងនាំប្អូនចូលហ្នឹង ម្ដាយម៉ឺងអ៊ីគាត់ដឹងទេ អ៊ំគាត់ដឹងទេ?

ភ៉ៈ ម៉ឺងក៏នៅអ៊ីក៏នៅគាត់ឲ្យមក មកចូលជាមួយគេទៅ ព្រោះយើងកូនកំព្រា អង្គការគេយកទៅចិញ្ចឹមកាលហ្នឹង ។

ប៊ុនថន: បាទ ។

ភ៉ៈ កាលនោះខ្ញុំនៅប្រធានកុមារនៅឡើយ ចេញពីភូមិឃុំមកអាយុប្រហែល១៤-១៥ ។

ប៊ុនថន: ចឹងឆ្នាំ៧០ហ្នឹងពេលពូចូលភ្លាមបានប្រធានកុមារ?

ភ៉ៈ បាទ ។

ប៊ុនថន: ប្រធានកុមារហ្នឹងគេឲ្យធ្វើអីខ្លះទៅ?

ភ៉ៈ ធ្វើស្រែចម្ការអប់រំដឹកនាំ ដឹកនាំកុមារមិនទាន់បានធ្វើស្រែចម្ការទេ កាលហ្នឹងធ្វើការអប់រំរៀនសូត្រឲ្យជួយបំផុសចលនាជំនាន់ខ្មែរក្រហមហ្នឹង ឲ្យចូលកងទ័ពដើម្បីវាយរបបលន់ នល់ ដែលទម្លាក់សម្ដេចសីហនុ ហ្នឹងប្រឆាំងជាមួយរបបលន់ នល់ ហ្នឹងដើម្បីវាយឈ្នះ ។

ប៊ុនថន: ចឹងពូមានតួនាទីអប់រំកុមារចឹងទៅ?

ភ៉ៈ បាទ! អប់រំខាងកុមារហើយអប់រំខាងនយោបាយដឹកនាំឲ្យប្រមូលកុមារប្រមូលឈ្លបដើម្បីចូលបម្រើការងាររបស់ខ្មែរក្រហម ។

ប៊ុនថន: បាទ ។

ភាៈ	ជួយបំផុសគ្នាឡើងឲ្យងើបឡើងតស៊ូប្រឆាំងជាមួយរបបជិះជាន់គឺលន់ នល់ ចឹង ។

ប៊ុនថនៈ	បាទ!ដល់ចឹងអប់រំនៅក្នុងភូមិទេ?

ភាៈ	បាទ! ក្រោយមកទៀតឆ្នាំ១៩៧២ខ្ញុំក៏ចេញមកបម្រើកងទ័ព ឆ្នាំ១៩៧២ខ្ញុំចេញមកកំពង់ធំ បណ្ដោយ ខ្ញុំកាន់អាវុធហ្នឹងនៅឆ្នាំ១៩៧២ ។

ប៊ុនថនៈ	កុមារមានចូលច្រើនទេ កាលពូធ្វើប្រធានកុមារ?

ភាៈ	អូស!ប្រជាជននោះ បាក់ស្អីក៏ដោយឲ្យថាកងទ័ពទៅទាំងអស់ ឲ្យតែកុមារអាយុ១៧-១៨ ឡើងទៅ ។

ប៊ុនថនៈ	ច្រើនហ្នឹងប៉ុន្មាននាក់នាក់ទៅ?

ភាៈ	ច្រើនក្នុងភូមិមួយៗយ៉ាងតិចពី១០ទៅ២០អីទៅ ២០នាក់ឡើងទៅ មួយសារហ្នឹងអត់ចេះទាស់ទេ ឲ្យតែបម្រើសម្ដេច ការងារជាតិហ្នឹងធ្វើហើយ ។

ប៊ុនថនៈ	បាទ!ចឹងនៅឆ្នាំ១៩៧២ហ្នឹង ពូចូលខាងកងទ័ពហ្នឹងអង្គការដេកមកឬមួយយ៉ាងម៉េច?

ភាៈ	អង្គការនាំមក គេហៅថាប្រធានសង្កាត់នោះ ប្រធានឃុំនោះគាត់អ្នកនាំមក ។

ប៊ុនថនៈ	ប្រធានឃុំមាននៅចាំឈ្មោះគាត់ទេ?

ភាៈ	ប្រធានសង្កាត់ឈ្មោះ វៃ បែកគាត់ហ្នឹង គាត់នាំចូលមកបាត់គាត់មិនដឹងថាទៅណាទៅណីទេ កាលហ្នឹង ។

ប៊ុនថនៈ	កាលហ្នឹងពូចូលទ័ពស្រុកឬមួយយ៉ាងម៉េច?

ភាៈ	ទ័ពស្រុក ។

ប៊ុនថនៈ	ស្រុកសណ្ដាន់ហ្នឹង?

ភាៈ	បាទ ។

ប៊ុនថនៈ	កាលហ្នឹងគេហៅស្រុកប៉ុន្មានស្រុកសណ្ដាន់ហ្នឹង?

ភាៈ	ស្រុកសណ្ដាន់ហ្នឹង មានប៉ុន្មានឃុំទេ ខ្ញុំវាមិនសូវចាំដែរ ។

ប៊ុនថនៈ	អត់ទេ គេមានដាក់លេខទេ?

ភាៈ	លេខអី ។

ប៊ុនថនៈ	លេខស្រុក ដូចថាស្រុក១៣ស្រុក១៥ចឹង?

ភាៈ	កាលហ្នឹងមួយសារច្បាំងមិនទាន់ដាក់លេខទេ ។

ប៊ុនថនៈ	ចឹងនៅស្រុកសណ្ដាន់?

ភាៈ	បាទ ។

ប៊ុនថនៈ	ហ្នឹងនៅក្នុងភូមិភាគឧត្តរឬ?

ភ៉ះ	បាទ!ភូមិភាគខាងទួរ អូស!ភូមិភាគកណ្តាលអីសណ្ដាន់ មិនដឹងថាខាងទួរអីកណ្ដាលទេ ភ្លេចហើយទេ ប្រហែលជាកណ្ដាលហើយ ខេត្តកំពង់ធំ ខេត្តកំពង់ចាម ភូមិភាគកណ្ដាល ភូមិភាគខាងទួរ ខេត្តសៀមរាបនេះ ។

ប៊ុនថន:	ចឹងសណ្ដាន់ភូមិភាគកណ្ដាល?

ភ៉ះ	បាទ ។

ប៊ុនថន:	ចឹងពូចេញពីភូមិមកហើយពេលចូលឆ្នាំ៧២ហ្នឹង?

ភ៉ះ	បាទ ។

ប៊ុនថន:	ចឹងមកនៅណា?

ភ៉ះ	ខ្ញុំចូលមកនៅកំពង់ធំនេះបណ្ដោយ មកកាន់អាវុធមកប្រចាំនៅខេត្តកំពង់ធំនេះ មិននៅក្នុងខេត្តទេ ខ្ញុំនៅជាយខេត្ត ទាហានរបប លន់ នល់ គេនៅក្នុងខេត្ត ។

ប៊ុនថន:	នៅម្ដុំណា?

ភ៉ះ	ខ្ញុំនៅម្ដុំព្រៃប្រស់ ។

ប៊ុនថន:	នៅម្ដុំព្រៃប្រស់រាល់ថ្ងៃគេបើកលក់បាយ?

ភ៉ះ	បាទ!ខ្ញុំទៅលេងស្រុកចូលហូបបាយនៅហ្នឹងដែរ ។

ប៊ុនថន:	ចឹងកាលពូមកព្រៃប្រស់គេមានបែងចែកជាកងឡើងវិញទេពូឬនៅជាទ័ពស្រុក?

ភ៉ះ	គេរៀបចំជាកង កងស្រុក ក្រោយមកឆ្នាំ៧២-៧៣-៧៤គេបំបែកជាកងតំបន់ គេរៀបចំធ្វើកងតំបន់ តំបន់ហ្នឹងមិនដឹងជាតំបន់ប៉ុន្មានទេ ភ្លេចបាត់ហើយ ។

ប៊ុនថន:	កងតំបន់តំបន់ប៉ុន្មានកាលហ្នឹង?

ភ៉ះ	ទេ តំបន់ប៉ុន្មានទេ ភ្លេចបាត់ហើយខេត្តកំពង់ធំហ្នឹង ភ្លេចបាត់ហើយអត់ចាំទេ ។

ប៊ុនថន:	ចឹងពូមកនៅព្រៃប្រស់ហ្នឹងជាទ័ពស្រុកសណ្ដាន់ទេ?

ភ៉ះ	បាទ ។

ប៊ុនថន:	ទាល់តែដល់៨៤បានបំបែកជាកងតំបន់?

ភ៉ះ	៧៤ ។

ប៊ុនថន:	៧៤?

ភ៉ះ	បាទ!មិនមែន៨០ទេ ។

ប៊ុនថន:	បាទ ។

ភ៉ះ	៧៤ហ្នឹងនៅទ័ពតំបន់វាយ ។

ប៊ុនថន:	តំបន់៤០ជាងពូ?

ភា៖ តំបន់៤០ដឹង ។

ប៊ុនថន៖ បាទ!មាន៤១-៤២-៤៣?

ភា៖ បាទ!ខេត្តណា ខេត្តកំពង់ធំ ។

ប៊ុនថន៖ បាទ!ភូមិភាគឧត្តរ ភូមិភាគកណ្តាល មានបីតំបន់ មានតំបន់៤១-៤២និង៤៣ កាលហ្នឹងពូនៅកងទ័ពតំបន់៤០ប៉ុន្មាន?

ភា៖ នៅតំបន់៤២មិនដឹង បែប៤២ហើយតាមមើល ។

ប៊ុនថន៖ ចឹងកាលហ្នឹងមានរៀបចេញជាកងពលអីទេ កាលហ្នឹង?

ភា៖ បាទ!មានកងពលភ្លេចអស់ទៅណា រៀបចូលក្នុងកងពលប៉ុន្មានទេ មួយសារនោះដល់យូរហើយខ្ញុំភ្លេចអស់ហើយ ។

ប៊ុនថន៖ ពូទទួលតួនាទីអីដែលកាលហ្នឹង?

ភា៖ មួយសារហ្នឹងធ្វើមេក្រុម ដឹកនាំដោយកងទ័ពវៀតណាមដែរ មួយសារនោះ ។

ប៊ុនថន៖ វៀតណាមខាងជើង?

ភា៖ បាទ!វៀតណាមខាងជើង ។

ប៊ុនថន៖ បញ្ចូលជាមួយគ្នា?

ភា៖ បញ្ចូលជាមួយគ្នា កាលហ្នឹងមិនមែនវៀតណាមសុទ្ធ គេថាភូមិភាគខាងជើងហ្នឹងខ្មែរយើងដែរតែទៅរៀននៅប្រទេសវៀតណាមជិតនាន់២៥ឆ្នាំហ្នឹង ។

ប៊ុនថន៖ ពីណា?

ភា៖ ពួកខ្មែរយើង រៀនវៀតណាមរៀនហាត់កងទ័ពហ្នឹង ចឹងពួកហ្នឹងត្រឡប់មក២៥ឆ្នាំហ្នឹង ពួកហ្នឹងជាអ្នកដឹកនាំធ្វើ មេកងពលកងវរៈអីហ្នឹង ។

ប៊ុនថន៖ មានចាំឈ្មោះគាត់ខ្លះទេ ពូ?

ភា៖ ឈ្មោះ បងខែម ។

ប៊ុនថន៖ ស្អីខែម?

ភា៖ អូស!មិនចាំទេ ។

ប៊ុនថន៖ កាលហ្នឹងគាត់ទទួលតួនាទីអី?

ភា៖ ប្រធានវរៈ ។

ប៊ុនថន៖ វរៈលេខប៉ុន្មាន?

ភា៖ កាលហ្នឹងមិនដឹងជាវរៈលេខប៉ុន្មានទេ ២៤មិនដឹងប៉ុន្មានទេ ខ្ញុំភ្លេចបាត់ហើយវាយូរណាស់ដែលហើយ ខ្ញុំភ្លេចអស់ហើយ ។

ប៊ុនថន: ចឹងពូនៅកងទ័ពតំបន់រហូតដល់ឆ្នាំ៧៥?

ភ៉ា: ៧៥ខ្ញុំនៅ មើលឆ្នាំ៧៤ ជិតចូល៧៥ខ្ញុំឡើងមកកងទ័ពមជ្ឈិម ខ្ញុំនៅកំពង់ចាម កងទ័ពមជ្ឈិម លេខប៉ុន្មានដូចជា៤០១ ។

ប៊ុនថន: ចឹង៤០១?

ភ៉ា: បាទ! ប្រចាំនៅម្តុំបន្ទាយស្រុកកំពង់ចាម ។

ប៊ុនថន: ប្រចាំនៅមន្ទីរអីវិញ?

ភ៉ា: មន្ទីរស៊ីប ។

ប៊ុនថន: មន្ទីរស៊ីប?

ភ៉ា: បាទ ។

ប៊ុនថន: ហ្នឹងនៅក្នុងភូមិឃុំស្រុកអីដែរ?

ភ៉ា: មន្ទីរស៊ីបមិនដឹងជាឃុំអីទេ នៅកន្លែងរោងចក្រចិនហ្នឹងណាស់ គេហៅមន្ទីរស៊ីបកន្លែងរោងចក្រហ្នឹងនោះ នៅប្រចាំនៅហ្នឹងរហូតដល់ឆ្នាំ៧៦ឆ្នាំ៧៧នៅប្រចាំហ្នឹង នៅកងពលហ្នឹងឈ្មោះតាហំ ស្លាប់អស់ហើយអត់មាននៅទេ ។

ប៊ុនថន: ឈ្មោះ តាហំ?

ភ៉ា: បាទ ។

ប៊ុនថន: ហ្នឹងគាត់ជាលេខាឬបញ្ជាការ?

ភ៉ា: មេកងពលតែម្តង ។

ប៊ុនថន: ស្អីហំ?

ភ៉ា: មិនដឹងជាស្អីហំទេ បើមិនបានស្រាវជ្រាវប្រវត្តិផង បើឥឡូវនេះយើងដឹងថាតាអីធ្វើមេជំនាន់ក្រោយ ។

ប៊ុនថន: ចឹងមិនមែនគ្រប់គ្រងផ្ទាល់ពីលើទេ មិនមែនខាងតាសុន សេន អីទេ?

ភ៉ា: អត់ទេ តាសុន សេន គាត់នៅលើផ្សេង ។

ប៊ុនថន: ចឹងពូដាច់ពីភូមិភាគហើយពេលឆ្នាំ៧៥ហ្នឹង?

ភ៉ា: ឆ្នាំ៧៥ខ្ញុំដាច់ពីតំបន់ហើយ ចូលមជ្ឈិមហើយ ។

ប៊ុនថន: ចូលមជ្ឈិមផុតពីភូមិភាគតំបន់អីហើយ?

ភ៉ា: បាទ ។

ប៊ុនថន: ចឹងអ្នកគ្រប់គ្រងខាងមជ្ឈិម?

ភ៉ា: បាទ ។

ប៊ុនថនៈ ពូនៅប្រចាំការនៅសិរីបហ្នឹង រហូតឬមានបញ្ជូនទៅ?

វ៉ាៈ រហូតដល់ឆ្នាំ៧៧-៧៨រដ្ឋប្រហារ រដ្ឋកម្ពុជាគេវាយ ។

ប៊ុនថនៈ ខាងណាវាយ រដ្ឋប្រហារខាងសោភឹមឬក៏?

វ៉ាៈ រដ្ឋប្រហាររបស់វៀតណាម មួយសារនោះមិននាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្វើរដ្ឋប្រហារទម្លាក់ពួកប៉ុល ពត ។

ប៊ុនថនៈ ខាងសោភឹមអីហ្នឹងខាងបូព៌ានិងពូ?

វ៉ាៈ បាទ! សោភឹម គាត់អត់មានមកវាយយើងទេ តែថាយើងនេះឯងខាងហ៊ុន សែន គាត់វាយពួកខ្មែរក្រហម នាំកម្លាំងវៀតណាមមកវាយនៅម្តុំព្រំដែន ។

ប៊ុនថនៈ ឆ្នាំ៧៨ពូ?

វ៉ាៈ បាទ! ៧៨ ។

ប៊ុនថនៈ ចឹងពូកាលហ្នឹងនៅណានៅបន្ទាយដែលឬបញ្ជូនទៅខាងព្រំដែន?

វ៉ាៈ គេបញ្ជូនទៅព្រំដែន ។

ប៊ុនថនៈ ទៅវាយនៅម្តុំណា?

វ៉ាៈ ទៅណាទេ ទៅប្រកអូរផ្អាវ មេមុត ក្រែក ។

ប៊ុនថនៈ វាយគ្នាខ្លាំងទេ?

វ៉ាៈ វាយជាមួយវៀតណាមវាយយូរដែលប្រហែលជិតមួយឆ្នាំដែរ បានចាញ់គេហ្នឹងណាស់៧៨ហ្នឹងដកមកវិញ ។

ប៊ុនថនៈ ៧៨ដក?

វ៉ាៈ បាទ! ដក ។

ប៊ុនថនៈ ចុង៧៨ឬមួយកណ្តាល?

វ៉ាៈ ចុង៧៨ ។

ប៊ុនថនៈ កាលហ្នឹងពីណាជាអ្នកដឹកនាំបញ្ជាឲ្យវាយផ្ទាល់?

វ៉ាៈ អ្នកដឹកនាំផ្ទាល់មានតែកងពលៗដូចតា កែ ពក ហ្នឹងភូមិភាគតែគាត់បញ្ជារៀបចំវាយតែយើងរៀបចំវាយមាន តាវ៉ាន់ តាសំ អីហ្នឹង ប្រធានកងពល ដឹងថាឈ្មោះ វ៉ាន់ ។

ប៊ុនថនៈ គាត់កងពលលេខប៉ុន្មាន?

វ៉ាៈ កងពលលេខ៨០៧ ។

ប៊ុនថនៈ កងពល៨០៧?

វ៉ាៈ បាទ ។

ប៊ុនថនៈ ចឹងឈ្មោះ សំ?

ភ៉ាៈ គាសំ ហ្នឹងដឹងប៉ុន្មានទេ ៤០៧ដឹង កាលហ្នឹងវាយតាមព្រំដែន ។

ប៊ុនថនៈ ហ្នឹងរបស់ភូមិភាគឬរបស់ខាងណា?

ភ៉ាៈ របស់ភូមិភាគ របស់មជ្ឈឹម ភូមិភាគបញ្ជាដែលកាលនោះ ។

ប៊ុនថនៈ ហើយពូនៅខាងមជ្ឈឹមវិញ ពូទៅដែរ?

ភ៉ាៈ បាទ!ទៅ ។

ប៊ុនថនៈ ទៅដំណាលគ្នាឬមួយមានមុនក្រោយពូ?

ភ៉ាៈ ទៅជាមួយគ្នាហ្នឹងឯងពេលដែលឆ្នាំ៧៧រហូតដល់៧៨-៧៩ នៅព្រំដែនហ្នឹងរហូតឆ្នាំ៧៩ ចាញ់បណ្ដោយ ។

ប៊ុនថនៈ កាលហ្នឹងពូទទួលនាទីអីដែរ នៅក្នុងកងពល៤០១ខាងមជ្ឈឹមហ្នឹង?

ភ៉ាៈ ខ្ញុំឡើងធ្វើជាប្រធាន«គ» ។

ប៊ុនថនៈ មួយកងពលមានប៉ុន្មាន«គ»?

ភ៉ាៈ មួយកងពលមានបី«ង» ។

ប៊ុនថនៈ មានបី«ង»?

ភ៉ាៈ បាទ!ក្នុងមួយ«ង»វាមានបីវរៈ ក្នុងមួយវរៈវាមានបី«គ» កាលហ្នឹង ។

ប៊ុនថនៈ មានបី«គ»?

ភ៉ាៈ បាទ!ខ្ញុំហ្នឹងប្រធាន«គ» ។

ប៊ុនថនៈ ប្រធាន«គ»ប៉ុន្មាន?

ភ៉ាៈ ខ្ញុំប្រធាន«គ១» តាំងពីនោះទៅយើងទៅដល់មេមុតដល់ឆ្នាំ៧៩ចាញ់ ក៏រត់មកឆ្លងនៅកំពង់ចាមវិញ ។

ប៊ុនថនៈ ឆ្លងតាមទន្លេមេគង្គហ្នឹង?

ភ៉ាៈ បាទ ។

ប៊ុនថនៈ ឆ្លងទៅខាងណាវិញ?

ភ៉ាៈ ឆ្លងមកម្តុំទន្លេបិតហ្នឹង ម្តុំកំពង់ចាមហ្នឹងឆ្លងត្រង់ហ្នឹង ហើយឆ្លងម្តុំស្ទឹងត្រង់ ។

ប៊ុនថនៈ ឆ្នាំ៧០ប៉ុន្មាន.?

ភ៉ាៈ ឆ្នាំ៧៩ ។

ប៊ុនថនៈ ឆ្លងស្ទឹងត្រង់ពូឆ្លងទៅខាងណាវិញ?

ភ៉ាៈ ឆ្លងមកខាងលិចទន្លេតែមកនៅម្តុំហ្នឹងស្រុកស្ទឹងត្រង់ នៅវាយគ្នាម្តុំហ្នឹងឯងហើយដល់ឆ្នាំ៨០ខ្ញុំឡើងមកភ្នំដងរែកវិញ ។

ប៊ុនថនៈ ឆ្នាំ១៩៨០មកតែពូឬមួយមកទាំងកងទ័ព?

ភ៉ាៈ កងទ័ពមកទាំងអស់ មានជាង១០០០នាក់មកទាំងអស់កាលហ្នឹង ។

ប៊ុនថនៈ ពូនៅដដែល?

ភ៉ាៈ ខ្ញុំឡើងវរៈហើយ ។

ប៊ុនថនៈ តែយើងនៅកងពលណាយើងនៅកងពលហ្នឹងដដែល?

ភ៉ាៈ បាទ! នៅដដែល ។

ប៊ុនថនៈ ពូនៅភ្នំដងរែកហ្នឹង ពូនៅម្តុំណា នៅម្តុំមុំបីឬនៅខាងណា?

ភ៉ាៈ នៅទល់មុខប្រាសាទព្រះវិហារ មុនដំបូងនៅមុំបីហ្នឹងឯង ឡើងតាមច្រក១០០១ នៅមុំបីបានមួយឆ្នាំបានផ្លាស់មកនេះមកនៅកងពលលេខ១២ ។

ប៊ុនថនៈ ចឹងនៅមុំបីហ្នឹងគេបែងចែកកងពលថ្មីហើយឬមួយនៅដដែល?

ភ៉ាៈ នៅដដែល ចេញមកនេះ ចេញពីមុំបីមក មកនៅព្រះវិហារនេះខ្ញុំនៅកងពល១២ ។

ប៊ុនថនៈ ខាងកងពល៦១២?

ភ៉ាៈ ៦១២ ។

ប៊ុនថនៈ ជាមួយអ៊ឹហឿន?

ភ៉ាៈ អ៊ឹហឿន ហ្នឹងហើយ អ៊ុន ហឿន ។

ប៊ុនថនៈ ចឹងឆ្នាំ៨០ហ្នឹងពូមកនៅខាងព្រះវិហារ?

ភ៉ាៈ បាទ ។

ប៊ុនថនៈ នៅលើប្រាសាទឬមួយនៅណា?

ភ៉ាៈ មុនដំបូងទៅនៅលើប្រាសាទ ចុះឡើងៗលើប្រាសាទហ្នឹង តែកងពល៦១២ប្រចាំលើប្រាសាទរហូត ខ្ញុំនៅជាមួយ អ៊ុន ហឿន ហ្នឹងខ្ញុំឡើងប្រធាន«ង»ហើយ ។

ប៊ុនថនៈ ប្រធាន«ង»ប៉ុន្មាន?

ភ៉ាៈ កាលហ្នឹង«ង៨៦» សព្វថ្ងៃភូមិនេះ«ង៨៦» ។

ប៊ុនថនៈ ចឹងបើដាក់តាមលេខគេហៅភូមិ«ង៨៦»?

ភ៉ាៈ បាទ ។

ប៊ុនថនៈ បើដាក់ភូមិ?

ភ៉ាៈ គេដាក់ភូមិសែនសុខវិញ ។

ប៊ុនថន: សែន សុខ ហ្នឹងឈ្មោះពីណាវិញ?

វ៉ាៈ ឈ្មោះ ចេះតែដាក់ទៅណា គេដាក់ក្រោយហ្នឹង សុខសប្បាយគេដាក់សែន សុខ បណ្ដោយទៅ ។

ប៊ុនថន: ចឹងប្រធាន«ង» កាលហ្នឹងកងទ័ពវៀតណាមឈរជើងនៅលើប្រាសាទឬក៏មិនទាន់មានទេ?

វ៉ាៈ កាលហ្នឹងខ្មែរក្រហមឈរជើង ។

ប៊ុនថន: ឆ្នាំ១៩៨០ហ្នឹង ឆ្នាំ៨០ហ្នឹងខ្មែរក្រហមឈរជើងលើប្រាសាទ?

វ៉ាៈ ទេ ៨០វៀតណាមនៅកាលនោះ ខាងរដ្ឋាភិបាលនៅ ដល់ឆ្នាំ៨៣-៨៤ពួកខ្ញុំមកវាយធ្លាក់ទាហានវៀតណាម ខាងខ្ញុំឈរជើងរហូតដល់៩៨បានខ្ញុំផ្ដាច់ខ្លួនចេញពីខ្មែរក្រហមចូលខាងរដ្ឋាភិបាល ។

ប៊ុនថន: និយាយពីខាងពូវាយបានពីខាងវៀតណាមវិញឆ្នាំណា?

វ៉ាៈ ទេ ៨៣ឬ៨៥មិនដឹងទេ ។

ប៊ុនថន: ចឹងឈរជើងច្រើនឆ្នាំចឹងតាំងពី៨៥ជាង១០ហើយ?

វ៉ាៈ ឈរជើងបានយូរណានៅម្ដុំហ្នឹង វៀតណាមចូលឈរជើងតាំងពីឆ្នាំ៨០នៅមែន តែយើង៨៥ពួកខ្ញុំវាយឈរជើងនៅនោះរហូតប្រចាំនៅហ្នឹងឯង វាយទាហានរដ្ឋាភិបាលទាហានវៀតណាមចុះចេញទៅ ។

ប៊ុនថន: តែខ្ញុំសួរខាងពូ វ៉ាន់ កុសល្យ ហ្នឹងគាត់ថាឆ្នាំ៩៣ ខាងកងទ័ពខ្មែរក្រហមវាយយកប្រាសាទព្រះវិហារបានពីកងទ័ពវៀតណាមនិងកងទ័ពរដ្ឋាភិបាល ហើយបានឈរជើងរហូតដល់ឆ្នាំ៩៨ហ្នឹង?

វ៉ាៈ អើ!ហ្នឹងហើយឆ្នាំ៩៣ដឹង ៩៣ហ្នឹងឯង ខ្ញុំភ្លេចបាត់ហើយ ៩៣ហើយ បងកុសល្យ អភិបាលស្រុក គាត់ជាប្រធានកងពល ។

ប៊ុនថន: គាត់ថាឆ្នាំ១៩៩៣បានវាយយកបាន?

វ៉ាៈ ហ្នឹងហើយ យើងវាយយកបានពីទាហានវៀតណាម ។

ប៊ុនថន: បាទ ។

វ៉ាៈ ចឹងយើងឈរជើងរហូត ទាល់តែឆ្នាំ១៩៩៨ ដែលខ្ញុំដាច់ចេញពីខ្មែរក្រហមខ្ញុំនាំកម្លាំងនៅជាមួយកងពល៨០១ហើយ មកនៅជាមួយបង០៥ ។

ប៊ុនថន: តាសារឿន ហ្នឹង?

វ៉ាៈ បាទ!មកនៅជាមួយតាសារឿនហ្នឹង ទទួលចាប់តាសារឿន តាម៉ុក និង ប៉ុល ពត ឈ្លួសគ្នាចាប់តាសារឿន វាយចោលអស់ទៅ ខ្មែរក្រហមគ្នាឯងហ្នឹង ខ្ញុំផ្ដាច់ខ្លួនចេញពីខ្មែរក្រហមចូល

ជាមួយរដ្ឋាភិបាលបណ្ដោយ នាំកម្លាំងប្រមូលទៅចំរុះបានជាង២០នាក់មាន២៧នាក់ទៅទាក់ទងជាមួយតាឌឹក បាននាំកម្លាំងរដ្ឋាភិបាលមកប្រាសាទព្រះវិហារ ។

ប៊ុនថន: ចឹងកាលពូមកព្រះវិហារមកនៅប្រាសាទឆ្នាំ៨០ហ្នឹង ពូមានឃើញថៃនៅឈរជើងនៅកន្លែងវត្តកែវ?

ភ៉ា: ថៃ អត់មានទេ មានតែខ្មែរយើងអត់មានថៃទេ ។

ប៊ុនថន: ចឹងថៃឈរជើងនៅណាវិញ?

ភ៉ា: ថៃ នៅឆ្ងាយណាស់ នៅកន្លែងផ្សារវ៉ាក្រោមនោះ ចម្ងាយដីប្រហែលជាមួយគីឡូ ពួកទាហានថៃ ។

ប៊ុនថន: កន្លែងផ្សារឈ្មួសគ្នាបច្ចុប្បន្នឬមួយនៅកន្លែងណា?

ភ៉ា: ផ្សារចេញពីជើងប្រាសាទទៅ គេហៅផ្សារស្អីទេ ត្រង់ហ្នឹង តាំងពីចប់សង្គ្រាមខ្ញុំមិនដែលទៅទេ ។

ប៊ុនថន: មិនមែនផ្សារដែលថៃ បាញ់ឆេះលើកមុនហ្នឹងទេ?

ភ៉ា: ផ្សារចម្ងាយប្រហែលប៉ុន្នានទេ ។

ប៊ុនថន: ផ្សារនៅជាប់ជើងប្រាសាទហ្នឹង?

ភ៉ា: អត់ទេ ។

ប៊ុនថន: ចឹងទៅមុខទៀត?

ភ៉ា: ហ្នឹងហើយ ។

ប៊ុនថន: ទៅដល់គេហៅផ្ទះក្រហមហ្នឹងទេ?

ភ៉ា: ហ្នឹងហើយផ្ទះក្រហមហ្នឹងឯង ឆ្ងាយទាហានថៃ មិនដែលបាននៅជិតហ្នឹងទេ ភាគច្រើនទាហានខ្មែរក្រហមនៅប្រចាំតាមហ្នឹងនោះ ខ្មែរទាំងអស់អត់មានថៃនៅជិតហ្នឹងបានទេ យើងកាន់កាប់ត្រង់ហ្នឹងទាំងអស់ ។

ប៊ុនថន: ចឹងផ្លូវចេញពីប្រាសាទក្រហមមកជើងប្រាសាទព្រះវិហារហ្នឹង មាននៅកាលហ្នឹង កាលពូនៅខាងព្រះវិហារហ្នឹង ផ្លូវកៅស៊ូមានបច្ចុប្បន្នហ្នឹងថៃធ្វើពីផ្ទះក្រហមហ្នឹងមកប្រាសាទព្រះវិហារមានហើយឬនៅសម័យពូនៅឈរជើងនៅហ្នឹង?

ភ៉ា: មួយសារនោះដូចជាមិនទាន់មានទេ មានតែមានគ្រួសក្រហម មិនទាន់មានចាក់កៅស៊ូទេ តែមិនមានផ្លូវកៅស៊ូទេ កាលនោះ ហើយក៏គ្មានថៃមកជិតផង ខ្ញុំតាមមើលប្រហែលជាមួយគីឡូផ្សារថ្មី ផ្សារក្រោយឆ្ងាយណាស់ ខ្ញុំឃើញថៃក្រហមៗទាហានថៃ អត់មានប្រជាជនមកស្នាក់ហ្នឹងទេ ។

ប៊ុនថន: បាទ ។

ភា: សុទ្ធតែទាហានថៃ ថៃអត់មានមកជិតក្បែរជើងប្រាសាទប្រហែល១០០ទៅ២០០ម៉ែត្រ ៣០-៤០-៥០ម៉ែត្រ១០០ម៉ែត្រអត់មានទេ មានត្រឹម៥០០ឡើង ថៃនៅថៃទៅក្រោយ មិនសួរបងកុសល្យ ចម្ងាយប៉ុន្មានពីនោះទៅ គាត់ដឹងតើ ចម្ងាយពីនោះទៅពីជើងប្រាសាទទៅទៅថៃ ។

ប៊ុនថន: ខ្ញុំបានសួរគាត់ដែរ គាត់ថាខាងថៃហ្នឹងមានទាហានមកបោះទីតាំងឈរជើងនៅកន្លែងប្រាសាទហ្នឹង តែអត់មានមកដល់វត្តកែវសិរីស្វារៈហ្នឹងទេ អត់មានមកដល់ហ្នឹងទេ ទៅខាងនោះប្រាសាទ ចឹងប្រាសាទហ្នឹងខាងថៃសាងសង់ឬមួយខាងខ្មែរ អាផ្ទះក្រហម?

ភា: ផ្ទះក្រហម ។

ប៊ុនថន: បាទ ។

ភា: ខ្ញុំពិបាកដែលត្រង់ហ្នឹង ផ្ទះក្រហមខ្ញុំមិនបានទៅមើលចប់សង្គ្រាម៩៨មកខ្ញុំមិនដែលបានទៅលេងប្រាសាទ រហូតដល់ឥឡូវ ខ្ញុំខ្ជិលខ្ញុំសន្យាថាឈប់ហើយចប់ ចប់សង្គ្រាមឈប់ធ្វើទាហានធ្វើអីទៅ ចូលកាត់ឈ្មោះអីអស់ទៅ ចូលខាងរដ្ឋាភិបាលរៀបចំកាល៩៨ខ្ញុំនាំកម្លាំងទៅផ្តាច់ខ្លួនចូលទៅខាងរដ្ឋមន្ត្រីហ៊ុន សែន ឯកឧត្តម មាស សុភា និងឯកឧត្តម កែវ គឹមយ៉ាន មកយកពួកខ្ញុំទៅភ្នំពេញ ទៅលេងបានបួនយប់បួនថ្ងៃ ពួកគាត់ជូនត្រឡប់មកវិញឲ្យរៀបចំកងទ័ពពួកខ្ញុំចាំនៅនេះ ប៉ុន្មានកងពល២៤ ។

ប៊ុនថន: កងពល២៤?

ភា: បាទ ។

ប៊ុនថន: នៅជាមួយពីណា?

ភា: នៅជាមួយ អ៊ុំ លាង នោះ ។

ប៊ុនថន: អ៊ុំ លាង?

ភា: បាទ!ដល់ អ៊ុំ លាង គាត់អាត្រែតអស់ហើយឥឡូវ ដល់ក្រោយមកឆ្នាំ២០១០ហ្នឹង ២០០៨-២០០៩ហ្នឹង បូកបញ្ចូលកងទ័ពជាមួយតាពឹម ។

ប៊ុនថន: យឹម ពឹម?

ភា: បាទ ។

ប៊ុនថន: កងពលប៉ុន្មានរំលាយចូលហ្នឹង?

ភា: កង២៤រំលាយចូលកងពលលេខប៉ុន្មានទេ ១២អីទេ ប៉ុន្មានទេ កាលហ្នឹងជាមួយតាពឹម រាល់ថ្ងៃហ្នឹងកងពលលេខ៨ លេខប៉ុន្មានទេ រាល់ថ្ងៃតាពឹម ហ្នឹង ។

ប៊ុនថនៈ ចឹងពេលពូមកនៅព្រះវិហារហ្នឹង ពូឈរជើងហ្នឹងឬមានចូលទៅវាយនៅណាទៀត?

រ៉ាៈ ក្រោយពីនោះមកខ្ញុំ ខ្ញុំមកឈរជើងនៅហ្នឹងឆ្នាំ៩៧ហើយ មកឈរជើងនៅប្រាសាទព្រះវិហារ ។

ប៊ុនថនៈ ឆ្នាំ៨០ពូចេញមកហ្នឹង?

រ៉ាៈ ពេលខ្ញុំមកនៅនេះ ។

ប៊ុនថនៈ ពេលចេញពីមុំបី?

រ៉ាៈ មកនៅប្រាសាទព្រះវិហារហ្នឹង មើលមកតាំងពីឆ្នាំ៨៥-៨៦ មកវាយតាមហ្នឹងឯងវាយតាមជើងប្រាសាទណាស់ យកបាននៅឆ្នាំ៩៧ តាសរ ថាង ទាហានរដ្ឋាភិបាលគេចាប់ហ្នឹងណាស់ ។

ប៊ុនថនៈ ចឹង៧៩ពូនៅមុំបីនៅ១០០១នោះទេ?

រ៉ាៈ ៧៩ខ្ញុំនៅស្រុកខ្មែរ ខ្ញុំនៅដល់ឆ្នាំ៨០បានខ្ញុំមកច្រក១០០១ គេហៅមុំបីហ្នឹងណាស់ ។

ប៊ុនថនៈ ចឹងពូមកនៅដល់៨៥បានឡើងមកវាយម៉ាដួរនេះ ឬមួយពូចល័តចុះឡើង?

រ៉ាៈ ដល់៨៥បានផ្លាស់មកនៅនេះបណ្ដោយមកនៅប្រាសាទព្រះវិហារហ្នឹង វាយតាមច្រកតាមផ្លូវដានមករហូតមកដល់ប្រាសាទព្រះវិហារ វាយកងពល៦១២របស់តាហឿន ។

ប៊ុនថនៈ ចឹងពូនៅរហូតដល់វាយយកបានប្រាសាទព្រះវិហារ ពូនៅជាមួយកងតាកុយ និងដែរ?

រ៉ាៈ ហ្នឹងហើយ នៅជាមួយតាកុយហ្នឹងឯង ។

ប៊ុនថនៈ កាលហ្នឹងតាកុយគាត់កាន់ខាងអី?

រ៉ាៈ តាកុយ គាត់កាន់កងពលដែលតើ តែគាត់ក្រោមរងទី៣ទី៤ ។

ប៊ុនថនៈ គាត់កងពល៦១២ដែរ?

រ៉ាៈ បាទ!គាត់ដូចថាកងពលជំនួយការរបស់កងពលណា ។

ប៊ុនថនៈ ពូពេលវាយនៅប្រាសាទព្រះវិហារហ្នឹង វាយជាមួយកងទ័ពវៀតណាមហ្នឹងវាយច្រើនទេពូទ័ពវាយ?

រ៉ាៈ ខាងខ្ញុំវាយម្ដងមាន៣០-៤០ទៅ៥០នាក់ ប៉ុណ្ណឹងឯង កងទ័ពវៀតណាមមកនៅវាយនៅអន្លង់ច្រកជុបរុននេះ ហួសប្រាសាទព្រះវិហារមកនៅនេះតាំងពី៨៣មក កាលហ្នឹងមានវៀតណាមរាប់រយវាយប្រហែល២០០ទៅ៣០០នោះ វាយយកភ្នំ វាយឈ្នះម្ដងពីរដង យើងអត់មានរត់ទៅណា ។

ប៊ុនថនៈ តែមានស្លាប់ច្រើនទេ ខាងកងទ័ពវៀតណាម?

វ៉ា: វាយម្ដងៗកងទ័ពវៀតណាមស្លាប់ច្រើនណាស់ដែរ ពួកយើងវាយចល័តទ័ពយើងអត់មានវាយជាខ្សែត្រៀមទេ ទាហានយើងតែ៥០នាក់ វាយជាមួយវៀតណាម២០០ទៅ៣០០ចឹងទៅ ។

ប៊ុនថន: បាទ ។

វ៉ា: កម្លាំងយើងវាយពីលិចវាយពីកើតវាយចល័តរហូត យើងអត់មានវាយ នៅមួយកន្លែងទេ ចឹងយើងស្លាបលពីរនាក់ ខាងវៀតណាមស្លាប់យ៉ាងតិចបួនដប់នាក់ដែរ ។

ប៊ុនថន: ចឹងពេលវាយបានចឹង ពូឈរជើងនៅលើប្រាសាទហ្នឹងតែម្ដង?

វ៉ា: បាទ!ឈរជើងលើប្រាសាទហ្នឹង ពិសេស បងកុសល្យ គាហឿន អីហ្នឹង តែខ្ញុំក៏ឈរជើងនៅប្រាសាទបានតែមួយភ្លេចទេ ខ្ញុំបង០៥គាត់ហៅទៅកំពង់ចាម ទៅនៅម្ដុំអូររាំងឪហ្នឹងហើយទៅនៅហ្នឹង ។

ប៊ុនថន: ចឹងពូចូលទៅធ្វើសកម្មភាពនៅខាងក្នុងវិញទេ?

វ៉ា: ធ្វើសកម្មភាពនៅក្នុង ។

ប៊ុនថន: ពេលវាយបានហើយនៅហ្នឹង?

វ៉ា: បាទ!វាយបានហើយ ប៊ុនឈរជើងនៅហ្នឹងឯង ។

ប៊ុនថន: ឆ្នាំ១៩៩៣?

វ៉ា: ហ្នឹងហើយ ។

ប៊ុនថន: ឈរជើងនៅអូររាំងឪកំពង់ចាម?

វ៉ា: បាទ ។

ប៊ុនថន: តែពូនៅកងពល៦១២ដដែលទេ?

វ៉ា: ខ្ញុំនៅ៨០១ ។

ប៊ុនថន: យ៉ាងម៉េចបានជាបំបែក៨០១ចឹងពូ?

វ៉ា: បាទ ។

ប៊ុនថន: យ៉ាងម៉េចបាបផ្ទូទៅ៨០១វិញ?

វ៉ា: កាលហ្នឹង៦១២នៅប្រចាំនេះ ចឹងគាត់ដកមួយវរសេនាធំខ្ញុំទៅធ្វើការកំពង់ចាម ចឹងគេបំបែកបញ្ជូនទៅ៨០១បណ្ដោយ ជាមួយគាពិន អីហ្នឹងនៅ៨០១ទាំងអស់ ពីដើមនៅ៦១២ទេ ។

ប៊ុនថន: នៅ៨០១ហ្នឹងពូទទួលតួនាទីអីវិញ?

វ៉ា: ប្រធាន“ង” ។

ប៊ុនថន: “ង”ហ្នឹងស្មើប្រធានវរសេនាធំដែរ?

ភ៉ៈ បាទ!“ង”ហ្នឹងប្រធានវរសេនាធំ ខ្មែរក្រហមហៅប្រធានវរសេនាធំ “ង”ហៅតាមទាហានវៀតណាម វៀតណាមគេហៅប្រធាន“ង” វៀតណាមហៅ“ង” ខ្មែរក្រហមហៅវរសេនាធំកាលហ្នឹង ។

ប៊ុនថនៈ ចឹងទទួល៨៦ដដែល?

ភ៉ៈ បាទ ។

ប៊ុនថនៈ ពូនៅហ្នឹងយូរទេ?

ភ៉ៈ នៅហ្នឹងមួយឆ្នាំ ពីរឆ្នាំនៅកំពង់ចាម ទៅ៩២ ឆ្នាំ៨៥ ។

ប៊ុនថនៈ ឆ្នាំ៨៥ចឹងក្រោយមិនទាន់វាយបានព្រះវិហារទេ?

ភ៉ៈ មិនទាន់វាយបានព្រះវិហារខ្ញុំត្រឡប់មកពីនោះវិញបានរួមជាមួយកងពល៦១២ហ្នឹងវាយយកប្រាសាទព្រះវិហារបានឈ្នះ ។

ប៊ុនថនៈ ចឹងពូមកពី?

ភ៉ៈ កំពង់ចាមវិញ ។

ប៊ុនថនៈ ចឹងពូមកពីកំពង់ចាមវិញ បានពូវាយយកប្រាសាទព្រះវិហារហ្នឹងបានពូចូលជាមួយកងពល៦១២?

ភ៉ៈ បាទ!ធ្វើការជាមួយគ្នាហ្នឹងឯង ។

ប៊ុនថនៈ ចឹងកាលពីមុនពូនៅ៨០១ទេ?

ភ៉ៈ ទេ មុនដំបូង៦១២ហ្នឹងឯង ដល់ក្រោយមកគេបំបែកទៅនៅនោះជាប់៨០១ ។

ប៊ុនថនៈ នៅ៨០១ដល់វាយព្រះវិហារបាន?

ភ៉ៈ ធ្វើការជាមួយគ្នាវិញ នៅ៨០១ដដែលតែធ្វើការនៅ៦១២ ។

ប៊ុនថនៈ ចឹងឆ្នាំ១៩៨៥ពូនៅកំពង់ចាម?

ភ៉ៈ បាទ!នៅកំពង់ចាមដល់បីឆ្នាំ បានខ្ញុំឡើងមកវិញ កាលនោះចុះឡើងៗមួយសារនោះដូចថាវាខ្ញុំមកធ្វើការនៅភ្នំទ្រព្យនេះ ប៉ះគ្នាវាយសន្ទប់ម្ដងពីរដងមាននេះណាឡើងវង្វេងអស់ហើយ របួសជាន់មីន ខ្វាក់ភ្នែកសន្ទប់ម្ដងពីរម្ដងមានណាឡើងវង្វេងអស់ហើយ របួសជាន់មីនខ្វាក់ភ្នែកនៅភ្នំទ្រព្យនេះ ។

ប៊ុនថនៈ វាយជាមួយវៀតណាមហ្នឹង?

ភ៉ៈ ហ្នឹងហើយ វាយនៅម្ដុំប្រកដុបរុនហ្នឹង ត្រូវសៀតថ្នាហ្នឹងសន្ទប់មួយយប់មួយថ្ងៃដេកនៅថៃនោះបានមួយខែ តាម៉ុក ដឹងទៅដល់ពេទ្យថៃ ។

ប៊ុនថនៈ កាលវាយនៅព្រះវិហារហ្នឹង វាយយកប្រាសាទព្រះវិហារហ្នឹង?

ភ៉ៈ បាទ!វាយយកប្រាសាទព្រះវិហារវាយយកជុបរុននេះឯង យួនវាយជាមួយយើង យើងវាយជាមួយវាហ្នឹង ។

ប៊ុនថនៈ ចឹងពូរបួសឆ្នាំប៉ុន្មាន?

ភ៉ៈ ខ្ញុំរបួសមួយសាររបួសភ្នែកហ្នឹងឆ្នាំ៩៨អូ!៨៨ កាលរបួសខ្ទាក់ភ្នែកហ្នឹងណាស់ ដល់ត្រូវក្បាលសន្ទប់មួយយប់មួយថ្ងៃហ្នឹងឆ្នាំ៨៣ របួសពីរបីដងខ្ញុំនោះ ត្រូវភ្នែកមួយសារត្រូវក្បាលមួយសារនោះណា ។

ប៊ុនថនៈ ចឹងត្រូវក្បាលមុនត្រូវភ្នែកឬត្រូវភ្នែកមុន?

ភ៉ៈ ត្រូវក្បាលមុន ក្បាលហើយបានភ្នែក ភ្នែក៩៨ហើយ ។

ប៊ុនថនៈ ៨៨?

ភ៉ៈ ៨៨ ។

ប៊ុនថនៈ បើ៩៨សមាហរណ៍កម្មហើយ?

ភ៉ៈ ៩៨បានសមាហរណ៍កម្ម ឆ្នាំ៨៨ដែលត្រូវភ្នែកនោះណា ។

ប៊ុនថនៈ ចឹងពេលពូត្រឡប់មកពីអូររាំងឪ ហើយបានពូមករួមជាមួយកងពល៦១២វាយនៅប្រាសាទព្រះវិហារ?

ភ៉ៈ បាទ ។

ប៊ុនថនៈ ចឹងបន្ទាប់ពីវាយឈ្នះហើយពូនៅឈរជើងនៅហ្នឹងរហូតឬមួយពីនៅណាទៀតពូ?

ភ៉ៈ នៅឈរជើងហ្នឹងរហូត ឈរជើងខាងបងកុសល្យ កងពល៦១២ចាស់ គាត់ឈរជើងនៅនោះខ្ញុំធ្វើការចុះឡើងទៅ មកនៅកំពង់ធំមួយរយៈប៉ុន្មាន៦ខែទៀត ទៅកំពង់ធំ មុំស៊ីងជីនិតឆ្នាំ៩៦-៩៧ហ្នឹង ៩៦ហ្នឹងឯង៩៧ទៅធ្វើការកំពង់ធំរយៈ៦ខែទៀត ។

ប៊ុនថនៈ ទៅមុំស៊ីងជីនិត?

ភ៉ៈ បាទ ។

ប៊ុនថនៈ ពូទៅហ្នឹងធ្វើអីខ្លះ?

ភ៉ៈ គ្រាន់ធ្វើការងារអប់រំប្រជាជនមិនដែលវាយទេ មិនដែលបានច្បាំងគ្នាទេ ជាមួយទាហានខ្មែរទាហានវៀតណាម ។

ប៊ុនថនៈ អប់រំយ៉ាងម៉េចវិញ?

ភ៉ៈ អប់រំកុំឲ្យជឿឃោសនារបស់វៀតណាមចេះៗ នាំឲ្យវាយកទឹកដីចេះចុះណាស់ អប់រំរបស់ខ្មែរក្រហមហ្នឹងឃើញចឹង ។

ប៊ុនថនៈ បាទ ។

ភ៉ាៈ ឲ្យខ្មែរយើងរួមគ្នា កាលហ្នឹង ។

ប៊ុនថេនៈ ពូនៅហ្នឹង៦ខែពូមកវិញ?

ភ៉ាៈ ឆ្នាំ៩៧ ខ្ញុំទៅបាន៦ខែគេដកមកវិញបានចូលដល់៩៨នេះ ផ្តាច់ខ្លួនណាស់ ។

ប៊ុនថេនៈ យ៉ាងម៉េចដែលពូអាចរៀបរាប់បានទេ ពេលត្រឡប់មកវិញ ពេលពូរៀបចំផ្តាច់ខ្លួន?

ភ៉ាៈ ខ្ញុំមកត្រឡប់មកវិញ មកធ្វើការនៅប្រាសាទព្រះវិហារចំនួន៦ខែទៀត បានចូល៩៨ ។

ប៊ុនថេនៈ បាទ ។

ភ៉ាៈ ចូល៩៨ខែ១ ថ្ងៃប៉ុន្មានមិនដឹងទេ ភ្លេចបាត់ហើយ ព្រោះឆ្នាំ១៩៩៨ខែ១ហ្នឹងខ្ញុំនាំកម្លាំងចំនួន២៧នាក់ ផ្តាច់ខ្លួនទៅជាមួយ អ៊ី លាង ទៅជួបខាងរដ្ឋាភិបាលខាងកងពលលេខ១២ ជាមួយ ស្រី ឌឹក ។

ប៊ុនថេនៈ អ្នកណាជាអ្នកនាំទៅ?

ភ៉ាៈ ខ្ញុំនាំនៅជាមួយ អ៊ី លាង ។

ប៊ុនថេនៈ ចឹង អ៊ី លាង គាត់អ្នកនាំទៅទាំងអស់?

ភ៉ាៈ បាទ!ខ្ញុំបានទាក់ទងគ្នាជាមួយ អ៊ី លាង ហ្នឹង មូលមតិគ្នាឯងភាពគ្នាក៏នាំគ្នាផ្តាច់ខ្លួនទៅ ។

ប៊ុនថេនៈ អត់មានពីណាដឹងទេ កាលហ្នឹង?

ភ៉ាៈ អត់ដឹងទេ យើងទៅដំបូងដល់ល្ងាចបានដឹងដល់នេះ ដល់តាហឿន តាអ៊ីហ្នឹង តាស៊ុន អ៊ីណាដល់ប្រាសាទព្រះវិហារ ។

ប៊ុនថេនៈ ចឹងកាលហ្នឹងតាជុំ ជាតិ នៅមុនហើយឬក៏យ៉ាងម៉េច?

ភ៉ាៈ កាលហ្នឹង តាជុំ ជាតិ ទៅមុនបានជិតមួយឆ្នាំរបស់គាត់ដែលហ្នឹង បានពួកខ្ញុំទៅ មានតាជុំ ជាតិ តាពីន អីហ្នឹងទៅមុន ។

ប៊ុនថេនៈ ចឹងពេលទៅហ្នឹងគ្រួសារអីយ៉ាងម៉េចដែរ?

ភ៉ាៈ កាលខ្ញុំទៅប្រពន្ធខ្ញុំនៅខ្មែរក្រហមនេះនៅឡើយទេ ដល់ចឹងខ្ញុំគេប្រាប់ទៅតាម៉ុកតាមគេអូ តាម៉ុក ថាឯងនាំកម្លាំងមកវិញ ឯងទៅនៅអីជាមួយអាយ៉ងយួនចេះចុះ ឯងប្រយ័ត្នប្រពន្ធកូនអត់មានបាយស៊ីវេទនានៅនេះមិនមកវិញ ខ្ញុំថាមិនទៅទេ បើឯងមិនទៅប្រយ័ត្ន គាត់ថាយ៉ាងម៉េចទេ កាលនោះ ។

ប៊ុនថេនៈ គាត់ថាយ៉ាងម៉េច?

ភ៉ាៈ គាត់ថាប្រពន្ធកូនឯងនៅលំបាកវេទនានេះ ខ្ញុំថាឥឡូវតាបញ្ជូនឲ្យខ្ញុំមកប្រពន្ធកូន អញមិនបញ្ជូនឲ្យទៅទេ ពួកឯង ចឹងតាឯងមិនបញ្ជូនប្រយ័ត្នខ្ញុំនាំកម្លាំងទៅរកកន្លែងនៅមិនបានតាម៉ុកគាត់ឆ្លើយថា មើលអា យួនពីរសែនប្រាំម៉ឺនវាយអញមិនឈ្នះ ចឹងគ្នាឯង២៧នាក់វាយអញ

ឈ្មោះដែរ ខ្ញុំថាយួនពីរសែនប្រាំម៉ឺន មិនស្គាល់ផ្ទះគាឯងទេ បើខ្ញុំវិញស្គាល់ណា បន្ទប់គដើង ត្រង់ណាក៏ដឹងដែរ គាម៉ុក ថាអត់អីទេ ចាំអញបញ្ជូនប្រពន្ធឯងទៅ ឯងមកទទួលម្ដុំហ្នឹងមក អើបើគាឯងមិនចូលរួមជាមួយរដ្ឋាភិបាលមិនចប់ទេ សង្គ្រាមកុំតាមអ្នកចាញ់ តាមអ្នកឈ្នះ ទៅរួមគ្នាខ្ញុំថាចឹង គាត់ថាអញមិនទៅទេ គាឯងនៅធ្វើអីទៀត គាឯងវាយមិនឈ្នះរដ្ឋាភិបាលទេ ចឹងអញអត់ឲ្យប្រពន្ធឯងទៅទេ ទាល់ឯងមកយក ចឹងខ្ញុំថាឯងបញ្ជូនឲ្យខ្ញុំមក បើគាឯងមិនបញ្ជូនប្រយ័ត្នងាប់ប្រពន្ធកូនខ្ញុំណាមួយ ប្រយ័ត្ននៅមិនសុខអន្ទង់វែង ចឹងចាំអញបញ្ជូនទៅ គាត់បញ្ជូនម្ដុំអន្លុងជុំ ។

ប៊ុនថន: បាទ ។

ភ៉ា: បញ្ជូនប្រពន្ធកូនខ្ញុំមកតាមអន្លុងជុំហ្នឹង មិនមែន២៧ទេ ៨៧ កាលហ្នឹងច្រឡំ ។

ប៊ុនថន: ពូនិយាយជាមួយគាត់ផ្ទាល់តែម្ដងឬមួយនិយាយជាមួយនិរសា?

ភ៉ា: និយាយជាមួយគាម៉ុក ផ្ទាល់ កាលហ្នឹងគាម៉ុក ដេ សម្បើមណាស់កាលហ្នឹង គាត់ថាឯងអាក្បាលខូច អាមេខូច នាំកម្លាំងចូលអាយ៉ងចេះចុះ ខ្ញុំថានៅហ្នឹងយ៉ាងម៉េចកើតបើច្បាំងមិនចេះចប់សង្គ្រាមចេះ ។

ប៊ុនថន: ចឹងពូមានអារម្មណ៍យ៉ាងម៉េច បើពូទៅប្រពន្ធកូននៅនេះ?

ភ៉ា: មានអារម្មណ៍ព្រួយដែរ គានោះបើយើងទៅម្នាក់ពីរនាក់ គេសម្លាប់ចោលប្រពន្ធកូនអត់ទៅទេ បើខ្ញុំនាំកម្លាំងទៅដល់៨៧នាក់ ចាំមើលទាំងអស់មាន៥០តែមកផ្ទះវិញបី ខ្ញុំនាំកម្លាំងទៅ៥០ នាក់កងពិសេសរបស់បង០៥ហ្នឹង កម្លាំងខាងខ្ញុំនាំមក កម្លាំងរបស់០៥ កម្លាំងដែលប្រយុទ្ធខ្លាំងមានតែកម្លាំងហ្នឹង បើកម្លាំងហ្នឹងទៅអស់មានពីណាប្រយុទ្ធទៀត ។

ប៊ុនថន: បាទ ។

ភ៉ា: ដល់ចឹងទៅក៏ប្រពន្ធកូនទៅពីនេះទៅ គាត់អត់ហ៊ានសម្លាប់ទេ យើងទៅគ្នាច្រើនចឹង បើសម្លាប់មួយដូចប្រពន្ធឈ្មោះ ឡុង ប៊ូរ៉េត ឈុន ប៊ុនរ៉េត ហ្នឹងគាត់ចេញទៅតែគាត់និងនិរសាគេសម្លាប់ចោលប្រពន្ធគាត់ ។

ប៊ុនថន: យ៉ាងម៉េចចឹង ចេញគិចគេសម្លាប់ចេញច្រើនអត់សម្លាប់?

ភ៉ា: ម៉េចហ៊ានសម្លាប់បើយើងគ្នាច្រើនហ៊ានសម្លាប់វាផ្ដើលមិនមែនតិចណារាប់រយហើយចុះប្រពន្ធ២៧ចុះកូនម្នាក់បី អាហ្នឹងមានតិចណារាប់រយណា ចឹងបើសម្លាប់អស់ពួកហ្នឹងប៉ុណ្ណឹងវាមិនផ្ដើលជិតចាញ់ហើយ ។

ប៊ុនថន: ចឹងពូនិយាយមិញហ្នឹង គាអីហ្នឹងឈ្មោះអីវិញ គាដែលថាសម្លាប់នោះ?

ភ៉ា: ០៥ ។

ប៊ុនថន៖ អត់ទេ គាត់រត់ចូលនោះ ចូលជាមួយរដ្ឋាភិបាលហើយប្រពន្ធត្រូវតាម៉ុក សម្លាប់នេះឈ្មោះអី ពីនិយាយមិញហ្នឹង?

ភ៉ា៖ ឈ្មោះ ឈុនប៊ុនរ៉េត ដែលគេសម្លាប់ប្រពន្ធគាត់ កាលហ្នឹងគាត់នៅកងពលលេខ៥ គាត់ផ្ដាច់ខ្លួនទៅ គាត់យកប្រពន្ធថ្មីមួយទៀតហើយ ។

ប៊ុនថន៖ ខាងណាសម្លាប់តាម៉ុក?

ភ៉ា៖ តាម៉ុក សម្លាប់ ទាំងប្រពន្ធកូនក្មួអស់ ប្ដីទៅបាត់ ។

ប៊ុនថន៖ ចឹងពូកាលហ្នឹង មានកូនប៉ុន្មាននាក់ កាលពូផ្ដាច់ខ្លួនហ្នឹង?

ភ៉ា៖ កូនខ្ញុំមាន៥នាក់ហើយ តែនៅតូចៗ ។

ប៊ុនថន៖ ពូការនៅឆ្នាំណា?

ភ៉ា៖ តាំងពីឆ្នាំ៨០ ។

ប៊ុនថន៖ កាលហ្នឹងការនៅណានៅ១០០១?

ភ៉ា៖ នៅ១០០២ហើយ ។

ប៊ុនថន៖ ១០០២?

ភ៉ា៖ ហ្នឹងហើយឆ្នាំ៨០ ។

ប៊ុនថន៖ ចឹងកាលហ្នឹងអង្គភាពរៀបចំឲ្យឬមួយពីស្នើ?

ភ៉ា៖ អង្គភាពរៀបចំឲ្យ តែមានតែខ្ញុំម្នាក់ឯងអត់មានមួយហ្វូងដូចជំនាន់កសាងទេណា ។

ប៊ុនថន៖ បាទ ។

ភ៉ា៖ ចុងឆ្នាំ៨០ ជិតចូល៨១ហើយខែ៤ហើយណា ។

ប៊ុនថន៖ ចឹងពូមានស្គាល់មីងពីមុនមកទេ ឬមិនដែលស្គាល់គ្នាទេ?

ភ៉ា៖ មិនដែលស្គាល់ទេ ទើបជួបគ្នាបានពីរបីខែ គាត់នៅដឹកជញ្ជូនខាងខ្មែរក្រហមហ្នឹង គាត់ដឹកជញ្ជូនខាងច្រកជរំអំពិលអីមក ធ្វើការជាមួយពួកខ្ញុំទៅ មកនៅដឹកជញ្ជូនមានស្រីច្រើនណា មិនតិចណាមានរាប់រយរាប់ពាន់ ។

ប៊ុនថន៖ ពូមានដឹងរឿងសម្លាប់ សុន សេន ទេ ពេលចុងក្រោយហើយនេះ?

ភ៉ា៖ សម្លាប់សុន សេន ។

ប៊ុនថន៖ បាទ! រឿងបែកបាក់គ្នាចុងក្រោយពូ?

ភ៉ា៖ រឿងបែកបាក់ចុហក្រោយ រឿងសម្លាប់សុន សេន ហ្នឹងខ្ញុំមិនបានដឹងថានរណាមួយសម្លាប់អត់ដឹងទេ ដូចខ្ញុំថាចឹងឆ្នាំ៩៧ហ្នឹងខ្ញុំនៅខាងកំពង់ធំណា ។

ប៊ុនថន៖ បាទ ។

រ៉ា:	ដល់ចឹងមានបញ្ហាហ្នឹងនៅឆ្នាំ៩៧ហ្នឹងឯង ឈ្លួសប្រកែកគ្នាតាម៉ុក តាប៉ុល ពត ហ្នឹងមិនដឹងថា នរណាមួយសម្លាប់ សុន សេន ហ្នឹង តាមពួកគេនិយាយគ្រប់គ្នាថា តាប៉ុល ពត បញ្ជាឲ្យគេ សម្លាប់ តែមិនដឹងថា នរណាមួយសម្លាប់ទេ ។

ប៊ុនថន:	ចឹងរឿងបែកបាក់ ប៉ុល ពត និងតាម៉ុក ពូមានដឹងទេ?

រ៉ា:	រឿងកម្លាំងផ្តាច់ខ្លួននៅប៉ៃលិននិងម៉ាឡៃ តាមដឹងខ្ញុំមិនបានចូលរួមប្រជុំទេ រាល់ដងខ្ញុំទៅប្រជុំ ជាមួយគាត់ ដល់ក្រោយមកឆ្នាំ៩៧មកខ្ញុំនៅកំពង់ធំនេះ ហើយតាមដំណឹងនិយាយពាក្យតៗ ទេ ពួកថា តាប៉ុល ពត ឲ្យតាម៉ុក ទៅធ្វើការនៅម៉ាឡៃ ប៉ៃលិនហ្នឹងឲ្យរៀបកម្លាំងខាងប៉ៃលិន ខាងអីហ្នឹងខាងអៀង សារី ហ្នឹងគាត់នាំកម្លាំងវាយជាមួយរដ្ឋាភិបាលចឹង តែកម្លាំងពួកហ្នឹង ផ្តាច់ខ្លួនមុន ផ្តាច់ខ្លួនចូលទៅខាងរដ្ឋាភិបាលទៅ តាប៉ុល ពត ខឹងតាម៉ុក តាមុត កូនប្រសារ របស់តាម៉ុក ផ្ទាល់ ចឹងបញ្ជាឲ្យកូនហ្នឹងវាយ តាម៉ុក ថាវាយយ៉ាងម៉េចកើត បើគាត់ម្នាក់ ឯងចឹង ចឹងគាត់ឈ្លួសគ្នាបែក គេហៅថាបែកកម្លាំងគ្នាបណ្តោយ តាប៉ុល ពត នៅលើតា ម៉ុក នៅក្រោម បំបែកគ្នាបានមួយខែដែលហ្នឹង ខ្មែរក្រហមនិងខ្មែរក្រហមវាយគ្នាហ្នឹងម្ខាង តាម៉ុក ម្ខាងតាប៉ុល ពត ។

ប៊ុនថន:	តាប៉ុល ពត មានពីណាខ្លះកាលហ្នឹង នៅខាងតាប៉ុល ពត មានពីណាខ្លះ?

រ៉ា:	មិនដឹងថា កងពលណាខ្លះទេ មួយសារហ្នឹង កងពលជាប់តាប៉ុល ពត ហ្នឹងក៏ទៅនៅហ្នឹងមាន ៨០១ខ្លះ មាន៦១៦ខ្លះ ពួកខាង៧៨៥ ។

ប៊ុនថន:	ចឹងមាន៧៨៥មានខាងណាទៀត?

រ៉ា:	៩៨០នៅជាមួយតាម៉ុក មានយឹម ពឹម អី នៅជាមួយតាម៉ុក ពាក់កណ្តាលមិនបែកជាកង ពលទាំងអស់ទេ ណាស់ ។

ប៊ុនថន:	បាទ ។

រ៉ា:	អាខ្លះពាក់កណ្តាលជាប់ខាងនេះទៅពាក់កណ្តាលជាប់ខាងនោះទៅគ្រប់កងពលហ្នឹង ។

ប៊ុនថន:	បាទ ។

រ៉ា:	អ្នកណាចូលចិត្តអ្នកនេះទៅខាងនេះទៅ អ្នកណាចូលចិត្តខាងនោះទៅខាងនោះទៅ ។

ប៊ុនថន:	ចឹងពូនៅខាងណាកាលហ្នឹង?

រ៉ា:	ខ្ញុំមានដឹងអី ខ្ញុំគ្មាននៅខាងណាទេ ព្រោះខ្ញុំនៅខាងកំពង់ធំឆ្នាំ៩៧ហ្នឹង មិនទាន់បាននៅជាមួយ ខាងណាទេ រឿងដែលឈ្លួសគ្នាហ្នឹង ខ្ញុំត្រឡប់មកដល់នេះវិញ ខ្ញុំនាំកម្លាំងផ្តាច់ខ្លួនទៅ បណ្តោយទៅ ខ្ញុំមកដល់កន្លែងវិញ ផ្តាច់ខ្លួនទៅជាមួយរដ្ឋាភិបាលបណ្តោយ ។

ប៊ុនថន:	ខាង៨០១ហ្នឹងតាសារឿន មែនទេ?

ភា៖ បាទ!តាសារឿន ប្រធានកងពលធំ ។

ប៊ុនថន៖ ចឹង៦១៦ពីណាវិញ?

ភា៖ តាញ៉ន ។

ប៊ុនថន៖ តាញ៉ន?

ភា៖ បាទ ។

ប៊ុនថន៖ ចឹង៧៨៥ពីណាវិញ?

ភា៖ ៧៨៥មានច្រើនមុខណាស់ ពួកភន ភន ៧៨៥ហ្នឹង ស្លាប់អស់ហើយពួកហ្នឹង ។

ប៊ុនថន៖ ចឹងខាងតាម៉ុក គាត់មានកងពល៩៨០?

ភា៖ បាទ ។

ប៊ុនថន៖ ចឹង៩៨០ពីណាវិញ?

ភា៖ ៩៨០មានពីណាពីណើខ្លះទេ កងពលផ្លាស់លិចផ្លាស់កើត ផ្លាស់ផ្លូវរហូត ។

ប៊ុនថន៖ មានតែមួយកងពលទេ ខាងតាម៉ុក មានកងពលអីទៀត?

ភា៖ ខាងតាម៉ុក មានច្រើនណាស់ ៨០១មានខាងតាម៉ុក ខ្លះ អ្នកនៅជាប់ខាងនេះទៅតាម៉ុក បញ្ជាទៅ អ្នកណានៅជាប់ជាមួយប៉ុល ពត ប៉ុល ពត បញ្ជាទៅ ប៉ុល ពត អត់មានជាប់ប៉ុន្មានទេ ជាប់តែប៉ុន្មាននាក់ហ្នឹងទេ អ្នកនៅជាប់កងពលជាប់ឈ្មោះ តែមេៗ កូនៗនៅក្រោមតាម៉ុក បញ្ជានេះ ។

ប៊ុនថន៖ បាទ ។

ភា៖ ចឹងនៅជាប់ជាមួយតាម៉ុក ហ្នឹងទៅ ។

ប៊ុនថន៖ ខាងប៉ុល ពត នៅខាងណា ប៉ែកខាងណា?

ភា៖ នៅក្បាលទន្លេរាងហ្នឹង ។

ប៊ុនថន៖ នៅក្បាលទន្លេរាងខាងតាម៉ុកនៅខាងអន្លង់វែង?

ភា៖ នៅខាងអន្លង់វែង ។

ប៊ុនថន៖ វាយគ្នា?

ភា៖ តាម៉ុក នៅជាំ គាត់ស្លាប់នៅជាំក្បាលទន្លេរាងនេះ ។

ប៊ុនថន៖ នៅហ្នឹងនៅភូមិឃុំអីវិញ កន្លែងប៉ុល ពត គាត់ស្លាប់ហ្នឹង?

ភា៖ មិនដឹងជាឈ្មោះ ភូមិអីទេ គេហៅថាកន្លែងជាំ គេហៅជាំហ្នឹងបណ្តោយរាល់ថ្ងៃច្រកអន្លង់វែង ហ្នឹងណា ។

ប៊ុនថន៖ ច្រកជាំហ្នឹង?

ភ៊ាៈ ហ្នឹងហើយ ច្រកដាំហ្នឹងហើយផ្ទះគាត់នៅហ្នឹងឯង ។

ប៊ុនថនៈ ចឹងវាយគ្នាហ្នឹងពូអត់ដឹងទេ ពូនៅខាងកំពង់ធំនោះទេ?

ភ៊ាៈ ដឹង តែខ្ញុំមកមិនទាន់ គេវាយគ្នាចប់ហើយបានខ្ញុំមកដល់ ។

ប៊ុនថនៈ ចឹងពេលមកដល់ពូចាប់ផ្តើមនាំជាមួយ អ៊ុ លាង ហ្នឹង នាំទ័ពទៅតែម្តង?

ភ៊ាៈ ហ្នឹងហើយ មកដល់គេដោះស្រាយគ្នាបង្រួបបង្រួមគ្នាហើយ ខ្ញុំក៏នាំកម្លាំងចេញមកបណ្តោយទៅ មើលទៅវាយមិនស្រួល ផ្តាច់ខ្លួនបណ្តោយទៅ ។

ប៊ុនថនៈ ចឹងបន្ទាប់ពីផ្តាច់ខ្លួនហើយពូនៅកងពលលេខប៉ុន្មានលេខ២៨ពូ ដែលរៀបចំវាយជាមួយខ្មែរក្រហមវិញ?

ភ៊ាៈ បាទ!មួយសារនោះចូលអត់មានកងពលទេ យើងនៅកម្លាំងដដែលយើងផ្តាច់ខ្លួនទៅនាំកម្លាំងរដ្ឋាភិបាលមានកងពលលេខ១មាន៥០នាក់កងពលលេខ១២មាន៥០នាក់ ស៊ុំឯកឧត្តម មាស សុភា កែវ គឹម យ៉ាន ដាក់បញ្ជូនមកវាយខ្មែរក្រហមវិញ សរុបទៅកងពលតាឌឹកហ្នឹងឲ្យ៥០នាក់ កងពលលេខ១ហ្នឹងឲ្យ៥០នាក់ មកដើម្បីបញ្ចប់សង្គ្រាម ខ្ញុំនាំកម្លាំងមកវាយបានតែមួយថ្ងៃពីរថ្ងៃគ្រាន់ពុសម្ដែងពួកខ្ញុំក៏ខ្មែរក្រហមលើកដៃទាំងអស់គ្នាទៅណា ។

ប៊ុនថនៈ បាទ ។

ភ៊ាៈ ថាយើងចូលរួបរួមគ្នាមកយើងកុំតស៊ូអីទៀត យើងតស៊ូគ្នាក៏មិនចប់ដែរ យើងរួបរួមគ្នាទៅបានចប់ វាយចប់អស់អន្លង់វែង បានឯកឧត្តម មាស សុភា គាត់យកយន្តហោះជាមួយតាកែវ គឹមយ៉ាន ហ្នឹងមកចុះនៅថ្លូវខាងអន្លង់វែងហ្នឹង យកពួកខ្ញុំឡើងទៅភ្នំពេញ កាលហ្នឹងមានផ្លូវអីចេះសុទ្ធតែព្រៃ ។

ប៊ុនថនៈ បាទ ។

ភ៊ាៈ ជិះយន្តហោះទៅ ។

ប៊ុនថនៈ ចឹងកាលទៅជួបគេដំបូងជួបពីណាវិញពូ?

ភ៊ាៈ ជួបទាហានរដ្ឋាភិបាលហ្នឹង ។

ប៊ុនថនៈ បាទ ។

ភ៊ាៈ ទៅជួបនៅខេត្តព្រះវិហារហ្នឹងបណ្តោយ ។

ប៊ុនថនៈ ទៅជួបតា ឃួយ គឹមហួន ហ្នឹងពូ?

ភ៊ាៈ បាទ ។

ប៊ុនថនៈ ទៅជួបពីណាឈ្មោះអីវិញ?

ភ៊ាៈ ទៅជួបឯងឧត្តម ស្រី ឌឹក នៅស្រុកជាំក្សាន្តនោះ ខេត្តព្រះវិហារហ្នឹង ជួបនៅហ្នឹងឯង ។

ប៊ុនថន: ចឹងបន្ទាប់ពីសមាហរណ៍កម្មហើយពីធ្វើអីទៀត?

វ៉ា: មកដល់រៀបចំកងពលខ្ញុំ គេរៀបចំនាយរងសេនាធិការមកពាក់សក្តិ៣ ខ្ញុំផ្តាច់ខ្លួនចេញមកខ្ញុំកាត់រំសាយទៅ នៅសក្តិរាល់ថ្ងៃក្នុងរូបថត ។

ប៊ុនថន: កាន់អីវិញ?

វ៉ា: នាយរងសេនាធិការ“ង” ។

ប៊ុនថន: ហ្នឹងនៅក្នុងកងពលប៉ុន្មានពូ?

វ៉ា: កងពល២៨ហ្នឹង កងពលរដ្ឋាភិបាលអ្នករៀបចំ កាលហ្នឹងមានចំរុះទ័ពកម្លាំងប៉ារាផងយើងផងចឹងរដ្ឋាភិបាលរាប់បែកគ្នា ខ្លះកាន់កងពលចុះមកនៅត្រឹម“ង” ។

ប៊ុនថន: “ង”ប៉ុន្មានកាលហ្នឹង?

វ៉ា: អាហ្នឹងមិនដឹងថា“ង”ប៉ុន្មានទេ ភ្លេចបាត់ហើយ“ង”ហ្នឹង ។

ប៊ុនថន: ចឹងនាយរងសេនាធិការពូពាក់សក្តិ៣?

វ៉ា: បាទ ។

ប៊ុនថន: ចឹងពូនៅរយៈពេលប៉ុន្មានបានពូមកធ្វើជាប្រធានភូមិនេះវិញ?

វ៉ា: ដល់ឆ្នាំ១៩៩០ប៉ុន្មានទេ ៩៨-៩៩ដឹង ៩៣ចឹងហើយខ្ញុំកាត់រំសាយ កាលហ្នឹងគេគាត់វគ្គ១ ។

ប៊ុនថន: ក្រោយសមាហរណ៍កម្ម៩៨ ឆ្នាំ២០០៣អីពូ?

វ៉ា: អូ!២០០៣ឆ្នាំ២០០០និង២០០៣ដែលខ្ញុំចូលសមាហរណ៍កម្មដែលខាងរដ្ឋាភិបាលរៀបចំកម្លាំងកាត់ចំនួន១០០០៥នាក់ ១០៥០០កាលហ្នឹង១៥០០០ កាលនោះកាត់រំសាយកងទ័ពច្រើនពេក ។

ប៊ុនថន: បាទ ។

វ៉ា: ចឹងខ្ញុំក៏ដាក់ឈ្មោះ កាត់រំសាយទៅទទួលអាយុវាច្រើនដង កាត់រំសាយវគ្គ១ ដល់ឆ្នាំ២០០០ហ្នឹងឯងកាត់រំសាយទៅកាលហ្នឹងគេកាត់ឆ្នាំ២០០០ហ្នឹងណាស់ ។

ប៊ុនថន: បាទ ។

វ៉ា: ឆ្នាំ២០០១ឆ្នាំ២០០៣ខ្ញុំឈរឈ្មោះ ធ្វើមេភូមិរហូតទាល់តែឥឡូវទៅពីដើមប្រពន្ធខ្ញុំមេភូមិកាលនោះ យាយហ្នឹងធ្វើមេភូមិតាំងពីឆ្នាំ៩៣មករហូតដល់ឆ្នាំ២០០៣ គេបោះឆ្នោតម្តងទៀត បោះឆ្នោតមេភូមិឈរឈ្មោះជាមួយខ្ញុំអីទៅ ខ្ញុំប្រធានប្រពន្ធខ្ញុំអនុ ដល់ហើយប្រពន្ធថាឈប់ហើយ ធ្វើទាំងអស់គ្នាមិនកើតទេ មានពីណាធ្វើស្រែ ។

ប៊ុនថន: បាទ ។

ភ៉ៈ មួយសារនោះ ប្រាក់ខែតិចពេក មានតែប្រធានទេ ប្រាក់ខែ២០០០០រៀលហើយអនុគ្នាអត់បាន ទើបឥឡូវទេ អនុក៏មានប្រធានក៏មាន ឥឡូវគេរៀបចំឲ្យប្រធាន១២០០០០ស្មើនិង៣០ដុល្លាក្នុងមួយខែ អនុបាន១០០០០០ សមាជិកបាន៨០០០០ ហ្នឹងឆ្នាំ២០១៨ទេ ណាស់ ។

ប៊ុនថន: បាទ ។

ភ៉ៈ បើរៀបចំមុននោះប្រធានបាន៦០០០០អនុបាន៥០០០០សមាជិកបាន៤០០០០ ចឹងដល់ចូលឆ្នាំ២០១៨នេះ បានគេចាប់ផ្ដើមបើប្រាក់១២០០០០បើក១០០០០០និង៨០០០០ក្នុងភូមិ ។

ប៊ុនថន: បាទ ។

ភ៉ៈ សមាជិកបាន៨អនុបាន១០ប្រធានបាន១២០០០០ ចឹងយើងកាច់មួយបានពីរ ។

ប៊ុនថន: បាទ ។

ភ៉ៈ គិតទៅដំឡើងបានពាក់កណ្ដាលម្នាក់ ។

ប៊ុនថន: ចឹងឥឡូវនៅជាមេភូមិដដែល?

ភ៉ៈ បាទ!មេភូមិដដែល ប្រាក់ខែសង្គមកិច្ចនៅបាន២៤០០០០ ។

ប៊ុនថន: ក្នុងមួយខែ២៤០០០០?

ភ៉ៈ បាទ!ប្រាក់ខែសង្គមកិច្ចបាន២៤០០០០ ឥឡូវគេផ្ទេរពីសង្គមកិច្ចចូលធនាគារអេស៊ីលីដា ។

ប៊ុនថន: បាទ ។

ភ៉ៈ ខែ១ឆ្នាំ២០១៨ហ្នឹងគេឲ្យទៅបើកលុយនៅធនាគារអេស៊ីលីដា ។

ប៊ុនថន: ចឹងខ្ញុំដូចជាអស់អីសួរពូដែលហើយ ពូមានអីចង់បន្ថែមទៀតទេ?

ភ៉ៈ អត់មានអីទេ ខ្ញុំមានតែប៉ុណ្ណឹងឯង ។

ប៊ុនថន: បាទ ។

ភ៉ៈ បាននិយាយប្រាជ្ញគ្នាលេងទៅ ។

ប៊ុនថន: បាទ!ចឹងអរគុណពូច្រើន ។

ភ៉ៈ បាទ ។

**ចប់**